ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកោះកុង

លេខ: ០២០/១៦ សសរ

ចូល លេខ: ៦២.៣៣ ទទួលថ្ងៃទី ៥ ខែ៧ ឆ្នាំ១៦ ម៉ោង ៩:០០

ធ្វើនៅកោះកុង,ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៦

## សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ របស់រដ្ឋបាលខេត្តកោះកុង ដើម្បីជំរុញការអនុវត្ត ការតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិ កំណែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ២០១៥-២០១៨

## អភិបាល នៃគណៈអភិបាលខេត្តកោះកុង

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការចាត់តាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៤១៣/៣៦៤ ចុះថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ២០១៣ ស្តីពីការត្រាស់បង្គាប់តែងតាំងអភិបាល នៃគណៈអភិបាលខេត្តកោះកុង សម្រាប់អាណត្តិទី២
- យោងលិខិតលេខ ១៨៤៦ មស.គករ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៦ របស់ក្រសួងមុខងារសាធារណៈ។

## សម្រេច

**ប្រការ១** ÷ ត្រូវបានបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ របស់រដ្ឋបាលខេត្តកោះកុង ដូចមានឈ្មោះក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ប៊ុន លើត** | អភិបាលខេត្ត | ប្រធាន |
| ២-លោក | **ស្រេង ហុង** | ប្រធានមន្ទីរមុខងារសាធារណៈខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៣-លោក | **អ៊ុច ឌុច** | នាយករដ្ឋបាលសាលាខេត្ត | សមាជិក |
| ៤-លោក | **ទេព វិសុទ្ធ** | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | សមាជិក |

៥-លោក **យិន ពិទាយ** ប្រធានធនាគារខេត្ត សមាជិក

៦-លោក **អភិបាលក្រុងខេមរភូមិន្ទ** សមាជិក

៧-លោក **អភិបាលស្រុក គ្រប់ស្រុក** សមាជិក

៨-លោក **ឡុង ពុទ្ធី** អនុប្រធានមន្ទីរមុខងារសាធារណៈខេត្ត ជាមន្ត្រីបង្គោល

៩-លោកស្រី **អ៊ុន សុគន្ធធិតា** អនុប្រធានមន្ទីរមុខងារសាធារណៈខេត្ត ជាមន្ត្រីបង្គោល

**ប្រការ២ ÷** ក្រុមការងារនេះ មានភារកិច្ចដូចខាងក្រោម៖

- ជាអង្គភាពសម្របសម្រួលការអនុវត្តការងារកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ត្រូវរាយការណ៍អំពីវឌ្ឍនភាពអោយបានទៀងទាត់រាល់ត្រីមាស ទៅលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៥-២០១៨។
- ក្រុមការងារនេះ មានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទក្នុងករណីចាំបាច់។

**ប្រការ៣ ÷** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៤ ÷** នាយករដ្ឋបាលសាលាខេត្ត អាជ្ញាធរក្រុង ស្រុក មន្ទីរ-អង្គភាពជុំវិញខេត្ត និងសាមីខ្លួនត្រូវអនុវត្តសេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**អភិបាល**

**អ៊ុន លើត**

**ចម្លងជូន**

-ក្រសួងមហាផ្ទៃ

-ក្រសួងមុខងារសាធារណៈ

-ក្រុមប្រឹក្សាខេត្ត

"ដើម្បីជូនជ្រាប"

-ដូចប្រការ១ និងប្រការ៤

"ដើម្បីសហការ អនុវត្ត"

-ឯកសារ កាលប្បវត្តិ